ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# មតិសំណេះសំណាល

## លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា ក្នុងកម្មវិធីពិនិត្យ និងព្យាបាល ភ្នែក-ត្រចៀក នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ស្រុកប្រាសាទសំបូរ, ថ្ងៃអាទិត្យ ទី៩ ខែមិថុនា ឆ្នាំ២០២៤

៙ ៙ ❖ ៚ ៚

ជាបឋម សូមគោរព

- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំធនាគាជាតិនៃកម្ពុជា
- លោក ឃឹម សុខឃាង អភិបាលស្រុកប្រាសាទសំបូរ
- លោក-លោកស្រី ក្រុមគ្រូពេទ្យស្ម័គ្រចិត្តខ្មែរ ក្រុមគ្រូពេទ្យមនុស្សធម៌សិង្ហបុរី ក្រុមយុវជនស្ម័គ្រចិត្ត
- លោកតា លោកយាយ ពូ មីង បងប្អូនប្រជាពលរដ្ឋ និងក្មួយៗនិស្សិតជាទីស្រលាញ់ទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកម្មវិធីនេះ!

ថ្ងៃនេះ ខ្ញុំនិងសហការី ព្រមទាំងក្រុមគ្រូពេទ្យស្ម័គ្រចិត្តទាំងអស់ មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលបានមកជួបលោកតា លោកយាយ ពូ មីង បងប្អូនប្រជាពលរដ្ឋព្រមទាំងក្មួយៗនិស្សិតទាំងអស់នៅទីនេះ ដែលលើកនេះជាលើកទី៥ ហើយដែលក្រុមការងារយើងខ្ញុំបានរៀបចំកម្មវិធីនេះ ប៉ុន្តែជាលើកទី១ សម្រាប់ស្រុកប្រាសាទសំបូរយើង ក្នុងការពិនិត្យនិងព្យាបាលភ្នែក និងត្រចៀក ដោយឥតគិតថ្លៃ។ ហើយយើងខ្ញុំក៏នៅតែបន្តជួយលោកតា លោកយាយ ពូ មីង បងប្អូនប្រជាពលរដ្ឋ និងក្មួយៗជាប់ជានិច្ច អស់ពីកំលាំងកាយចិត្ត និងមិនខ្លាចនឿយហត់ឡើយ។ លោកតា លោកយាយ ពូ មីង បងប្អូនប្រជាពលរដ្ឋ និងក្មួយៗ ប្រសិនបើប្រទេសជាតិយើងពុំមានសុខសន្តិភាពពេញលេញ មានការរីកចម្រើន មានភាពសម្បូរសប្បាយដូចសព្វថ្ងៃ និងមានផ្លូវថ្នល់ អាគារសិក្សា ដូចនៅទីនេះជាដើមនោះទេ យើងខ្ញុំពិតជាពុំអាចមកចុះជួយចែករំលែកទុក្ខធុរៈ ការលំបាករបស់ លោកតា លោកយាយ ពូ មីង បងប្អូនប្រជាពលរដ្ឋ ដូចថ្ងៃនេះឡើយ។ សូមអរគុណសន្តិភាព!



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមពាំនាំនូវការសាកសួរសុខទុក្ខ និងសេចក្តីនឹករឭកពី ឯកឧត្តម បណ្ឌិត **ជា ចាន់តូ** ទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា និងលោកជំទាវ **ខៀវ ស៊ីណា** ដែលលោកទាំងពីរតែងតែយកចិត្តទុកដាក់ និងគិតគូរពីសុខទុក្ខប្រជាពលរដ្ឋនៅក្នុងស្រុកប្រាសាទសំបូរ ក៏ដូចជាប្រជាពលរដ្ឋទូទាំងខេត្តកំពង់ធំយើងជានិច្ច។

គិតចាប់ពីឆ្នាំ២០១៧ មកដល់បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តជំនាញខាងភ្នែក-ត្រចៀកជាច្រើនទាំងក្នុងស្រុក និងបរទេស ដូចជា មកពីមូលនិធិ-ចក្ខុខ្មែរ (Khmer Sight Foundation) អង្គការរក្សាកុមារ អង្គការផ្តល់នូវក្តីសង្ឃឹមកម្ពុជា (HOPE Cambodia) ក្រុមគ្រូពេទ្យជំនាញមកពីចក្រភពអង់គ្លេស ប្រទេសអាល្លឺម៉ង់ និងអង្គការជំនួយមនុស្សធម៌សុខភាពអូស្ត្រាលី ដែលបានមកបំពេញបេសកកម្មពិនិត្យ និងព្យាបាល ភ្នែកនិងត្រចៀក ជូនប្រជាពលរដ្ឋក្នុងខេត្តកំពង់ធំ បានប្រមាណជាង ៦ពាន់នាក់ ហើយទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ប្រកបដោយសេចក្តីរីករាយ និងស្នាមញញឹមពោរពេញដោយក្តីសង្ឃឹម។

ធនាគារជាតិនៃកម្ពុជាបានប្រឹងប្រែងបន្តបំពេញបេសកកម្មមនុស្សធម៌នេះជាទៀងទាត់នៅពេលមានឱកាស និងធនធានអំណោយផល ដូចបានជម្រាបជូនពីដំបូងមកគឺយើងខ្ញុំបានចាប់ផ្តើមតាំងពីឆ្នាំ២០១៧ ប៉ុន្តែជាអកុសលនៅពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩ បេសកកម្មនេះត្រូវបានផ្អាកអស់រយៈពេល ២ឆ្នាំ គឺនៅឆ្នាំ២០២០ និងឆ្នាំ២០២១។ បន្ទាប់ពីស្ថានភាពជំងឺកូវីដ-១៩ ត្រូវបានគ្រប់គ្រងបាន ធនាគារជាតិនៃកម្ពុជាក៏បានប្រឹងប្រែងធ្វើការទំនាក់ទំនងទៅកាន់បណ្តាដៃគូជាអង្គការមនុស្សធម៌ឡើងវិញ ដើម្បីបន្តបេសកកម្មនៃការផ្តល់ស្នាមញញឹម និងក្តីសង្ឃឹមជូនប្រជាពលរដ្ឋនៅក្នុងខេត្តកំពង់ធំយើងនេះឡើងវិញដោយមិនបង្អង់។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ ដែលដឹកនាំដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលជាប្រមុខរាជរដ្ឋាភិបាលនៅតែបន្តយកចិត្តទុកដាក់បន្តជួយរំលែកការលំបាក ទុក្ខធុរៈរបស់ប្រជាពលរដ្ឋនៅស្រុកប្រាសាទសំបូរនេះ ដោយបានចាត់តាំង និងផ្តល់ឱកាសឱ្យយើងខ្ញុំដែលមានថ្នាក់ដឹកនាំរបស់ធនាគារជាតិនៃកម្ពុជា រួមមាន ដូចជា **របខ្ញុំផ្ទាល់ លោកជំទាវ សាយ សំអាត ឯកឧត្តម យឹម លាត ឯកឧត្តម អ៊ូ ចាន់តារា ឯកឧត្តម ហេង បូមករា (បេសកកម្មក្រៅប្រទេស) លោកយុ វុណ្ណី ជាដើម និងសមាជិករាជរដ្ឋាភិបាលដទៃទៀត** ដើម្បីមកចុះជួយលោកតា លោកយាយ ពូ មីង បងប្អូនប្រជាពលរដ្ឋ និងក្មួយៗ។ ជាក់ស្តែង ថ្ងៃនេះ ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសរុបប្រមាណ ៣៥រូប មកពីអង្គការមនុស្សធម៌នៃក្តីស្រលាញ់ (Humanitarian with Love) របស់ប្រទេសសិង្ហបុរី មូលនិធិចក្ខុខ្មែរ និងអង្គការផ្តល់នូវក្តីសង្ឃឹមកម្ពុជា រួមជាមួយក្រុមយុវជនស្ម័គ្រចិត្តធនាគារជាតិនៃកម្ពុជាចំនួន ៥០រូបទៀត សរុបប្រមាណ ៨៥រូប បានមកដល់ទឹកដីស្រុកប្រាសាទសំបូរនៃខេត្តកំពង់ធំយើង ដើម្បីផ្តល់ជូនការពិនិត្យ និងព្យាបាលភ្នែក-ត្រចៀក ដោយឥតគិតថ្លៃ ជូនលោកតា

លោកយាយ ៣ មីង និងបងប្អូនប្រជាពលរដ្ឋក្នុងស្រុកប្រាសាទសំបូរ សរុបប្រមាណជាង ១.៤០០នាក់ ក្នុងទីកន្លែងដ៏ធំទូលាយរបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាលនេះសម្រាប់បំពេញការងារមនុស្សធម៌នេះ ដែលអាចទទួលពិនិត្យ និងព្យាបាលជូនប្រជាពលរដ្ឋ បានច្រើន និងមានភាពងាយស្រួល។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកយាយ លោកតា បងប្អូន ៣មីង និងក្មួយៗ ជាទីរាប់អាន!**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាលនេះ ជាកន្លែងបណ្តុះបណ្តាលជំនាញ និងធនធានមនុស្សប្រកបដោយគុណភាពបានច្រើនជំនាន់មកហើយ ហើយសិស្សនិស្សិតដែលបញ្ចប់ការសិក្សានៅវិទ្យាស្ថាននេះ ភាគច្រើនមានសមត្ថភាពរៀនបន្តទៀត និងមានមុខរបរ និងការងារ ដែលទទួលបានប្រាក់ចំណូលសមរម្យ ខ្ញុំសូមកោតសរសើរដល់ការខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រងវិទ្យាស្ថានដែលបានដឹកនាំបេសកកម្មបណ្តុះបណ្តាលជំនាញបច្ចេកទេសបានដោយរលូន និងមានប្រសិទ្ធផល និងសិស្សនិស្សិតផ្ទាល់ដែលខិតខំក្រេបយកចំណេះនិងជំនាញពីវិទ្យាស្ថាន ដើម្បីពង្រឹងសមត្ថភាពបំពេញការងារបម្រើសង្គម ក៏ដូចជាសេដ្ឋកិច្ចគ្រួសារ និងខ្លួនឯង។ វិទ្យាស្ថាននេះត្រូវបានដំណើរការទៅក្រោមគម្រោងជំនួយឧបត្ថម្ភរយៈពេលជាច្រើនឆ្នាំមកហើយរបស់ព្រះអង្គម្ចាស់ក្សត្រិយ៍ សិរិនថន និងកិច្ចសហការផ្សេងៗទៀតជាមួយដៃគូក្នុងស្រុក និងក្រៅស្រុក។ ឯកឧត្តមបណ្ឌិត ជា ចាន់តូ ទេសាភិបាលកិត្តិយស ក៏បានចូលរួមឧបត្ថម្ភថវិកាសម្រាប់កិច្ចដំណើរការការងាររបស់វិទ្យាស្ថាន និងការសាងសង់បុស្បុកតម្កល់ព្រះហរិហរៈមារពិជ័យប្រចាំវិទ្យាស្ថាននេះផងដែរ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកយាយ លោកតា បងប្អូន ៣មីង ជាទីរាប់អាន**

រាជរដ្ឋាភិបាលកម្ពុជា ដែលមានអាយុ៩ខែ ដឹកនាំដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាអ្នកបន្តមរតកដឹកនាំក្រោមដំបូលសន្តិភាពពី**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បាននិងកំពុងធ្វើដំណើរទៅមុខយ៉ាងស្វាហាប់ និងបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យសំខាន់ៗនានាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក្នុងនោះមាន យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងវិស័យអាទិភាពចំនួន ៦ទៀត ដែលជាផែនទីចង្អុលផ្លូវសម្រាប់ការកសាង ការពារ និងអភិវឌ្ឍមាតុភូមិ។ ជាក់ស្តែង ក្នុងរយៈពេល ៩ខែកន្លងទៅនេះ រាជរដ្ឋាភិបាលដែលដឹកនាំដោយអ្នកជំនាន់ថ្មី សម្រេចបានសមិទ្ធផលជាផ្លែផ្កាយ៉ាងច្រើនគួរឱ្យសម្គាល់។

ដោយឡែក វិស័យសុខាភិបាលដែលជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំង៦ របស់រាជរដ្ឋាភិបាល ត្រូវបាននិងកំពុងបន្តពង្រឹងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលបំណង

ពង្រឹងសុខមាលភាពប្រជាពលរដ្ឋឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល តាមរយៈ ១/- ការពង្រីកសេវាសុខាភិបាលរហូតដល់ទៅ ៧ថ្ងៃ/២៤ម៉ោង នៅតាមបណ្តាមន្ទីរពេទ្យ និងមណ្ឌលសុខភាព ២/- ការដាក់សម្ពោធមន្ទីរពេទ្យបង្អែកនៅសៀមរាប ដែលអាចទទួលព្យាបាលអ្នកជំងឺធ្ងន់ធ្ងរមកពីខេត្តនៅក្បែរនោះ (មន្ទីរពេទ្យបង្អែកប្រចាំតំបន់) ៣/- ការពង្រឹងសមត្ថភាព និងគុណភាពគ្រូពេទ្យ និងបរិក្ខារពេទ្យនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព និង៤/- ការបំពាក់ប្រព័ន្ធអ៊ិនធើណែតសម្រាប់ក្រុមគ្រូពេទ្យនៅតាមបណ្តាខេត្តអាចទាក់ទងពិគ្រោះយោបល់ជាមួយក្រុមគ្រូពេទ្យនៅភ្នំពេញ ជាដើម។ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍នេះ បេសកកម្មមនុស្សធម៌ដែលធនាគារជាតិនៃកម្ពុជាបាន និងកំពុងប្រឹងប្រែងផ្តល់ជូនប្រជាពលរដ្ឋយើងនៅពេលនេះ អាចចូលរួមចំណែកក្នុងការធ្វើឱ្យសុខភាពភ្នែក-ត្រចៀករបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ដើម្បីអាចមានលទ្ធភាពចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចកាន់តែសកម្មឡើងថែមទៀត ដែលជាផលវិជ្ជមានទៅដល់ការជំរុញកំណើនសេដ្ឋកិច្ចជាតិទាំងមូលផងដែរ។

ឆ្លៀតក្នុងឱកាសនេះ នាងខ្ញុំសូមចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំ ជាមួយក្រុមគ្រួសារជនរងគ្រោះក្នុងករណីលិចទូកចម្លងត្រង់ចំណុចត្នោតជួរ-ឈូក កាលពីម្សិលមិញនេះ ដែលជាហេតុការណ៍មួយគួរឱ្យសោកស្តាយ។ ឧប្បត្តិហេតុនេះគឺជាហេតុការណ៍មួយ ដែលយើងមិនចង់ឱ្យកើតមានឡើង។ ហេតុនេះ ដើម្បីចូលរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ជាយថាហេតុ នាងខ្ញុំសូមចូលរួមឧបត្ថម្ភអាវពោងចំនួន៤០ សម្រាប់ក្មួយៗសិស្សានុសិស្សក្នុងការធ្វើដំណើរតាមទូកចម្លង នាពេលបច្ចុប្បន្ន។ ជាមួយគ្នានេះ នាងខ្ញុំក៏បានណែនាំឱ្យក្រុមការងារសហការជាមួយក្រុមការងារខេត្ត ដើម្បីសិក្សាពីលទ្ធភាពនៃការសាងសង់ស្ពានសម្រាប់ក្មួយៗសិស្សានុសិស្ស ក៏ដូចជាប្រជាពលរដ្ឋ ដើម្បីជាមធ្យោបាយធ្វើដំណើរក្នុងជីវភាពប្រចាំថ្ងៃផងដែរ។ ទន្ទឹមនេះ នាងខ្ញុំក៏សូមសំណូមពរឱ្យក្មួយៗសិស្សានុសិស្ស ឪពុកម្តាយ ព្រមទាំងអ្នកចម្លងទូកឱ្យបង្កើនការប្រុងប្រយ័ត្ន និងសំណូមពរដល់អាជ្ញាធរមានសមត្ថកិច្ចជួយពិនិត្យបន្ថែមលើអ្នករកស៊ីចម្លងទូក ដើម្បីធានាសុវត្ថិភាពដល់ក្មួយៗសិស្សានុសិស្ស ក៏ដូចជាប្រជាពលរដ្ឋក្នុងការប្រើប្រាស់ ចៀសវាងមានឧប្បត្តិហេតុដូចកាលពីម្សិលមិញនេះ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកយាយ លោកតា ពូមីង បងប្អូនទាំងអស់ ជាទីរាប់អាន!**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងអស់ពីដួងចិត្តជូនចំពោះក្រុមគ្រូពេទ្យស្ម័គ្រចិត្ត និងក្រុមយុវជនស្ម័គ្រចិត្តធនាគារជាតិទាំងអស់ ព្រមទាំងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ចំពោះការខិតខំប្រឹងប្រែងយ៉ាងសកម្មដោយមិនខ្លាចនឿយហត់ ដែលបានចូលរួមរៀបចំកម្មវិធីនេះឡើង។ ទន្ទឹមនេះខ្ញុំក៏សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះលោកនាយកវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ដែលបានផ្តល់ទីតាំងសម្រាប់ពិនិត្យភ្នែក-ត្រចៀកជូនប្រជាពលរដ្ឋ និងកម្មវិធីនាថ្ងៃនេះផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមធ្វើការអំពាវនាវដល់ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកយាយ លោកតា អ៊ុំ ពូមីង ប្អូនៗនិស្សិតទាំងអស់ បន្តគាំទ្រគោលនយោបាយរាជរដ្ឋាភិបាលថ្មី ដែលដឹកនាំដោយ**សម្តេចធិបតី ហ៊ុន ម៉ាណែត** ដើម្បីប្រទេសជាតិយើងបន្តទទួលបានសុខសន្តិភាព ស្ថិរភាពនយោបាយ និងជាពិសេសបន្តទទួលបានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោកអភិបាលស្រុកប្រាសាទសំបូរ លោក-លោកស្រី លោកតា លោកយាយ ពូ មីង ក្រុមគ្រូពេទ្យមនុស្សធម៌ ក្រុមយុវជនស្ម័គ្រចិត្ត និងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យដំណើរការនៃការពិនិត្យ-ព្យាបាលភ្នែក-ត្រចៀករយៈពេល ៣ថ្ងៃ (ដែលបានចាប់ផ្តើមតាំងពីម្សិលមិញមក) ប្រព្រឹត្តិទៅដោយរលូន និងទទួលបានជោគជ័យ។

**សូមអរគុណ!!!**